**ព្រះរាជាណាចក្រកម្ពុជា**

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

**លេខ:..១១..អនក្រ.បក**

# អនុក្រឹត្យ
# ស្តីពី
# ការរៀបចំនិងការប្រព្រឹត្តទៅរបស់ខុទ្ទកាល័យនាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី និងរដ្ឋលេខាធិការជាប្រធានស្ថាប័ន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៣/០១២ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា២៨នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ៥០ អនក្រ.បក ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ១៩៩៩ ស្តីពីការស្ថិតនៅក្រៅក្របខ័ណ្ឌដើម ចំពោះមន្ត្រីរាជការស៊ីវិល មន្ត្រីតុលាការ មន្ត្រីនគរបាលជាតិ និងកងយោធពលខេមរភូមិន្ទ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

## សម្រេច
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះមានគោលបំណងកំណត់ការរៀបចំ និង ការប្រព្រឹត្តទៅរបស់ខុទ្ទកាល័យនាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី និងរដ្ឋលេខាធិការជាប្រធានស្ថាប័នចំណុះរាជរដ្ឋាភិបាល។

**មាត្រា២.-**

អនុក្រឹត្យនេះមានគោលដៅកំណត់៖

- ការបង្កើតខុទ្ទកាល័យរបស់នាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី និងរដ្ឋលេខាធិការជាប្រធានស្ថាប័ន
- រចនាសម្ព័ន្ធនិងភារកិច្ចរបស់ខុទ្ទកាល័យ
- មុខតំណែងនិងប្រាក់បំណាច់សម្រាប់មុខតំណែងនីមួយៗក្នុងខុទ្ទកាល័យ។

**មាត្រា៣.-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះខុទ្ទកាល័យនាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី និងរដ្ឋលេខាធិការជាប្រធានស្ថាប័នចំណុះរាជរដ្ឋាភិបាល។

## ជំពូកទី២

## ខុទ្ទកាល័យនាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី និងរដ្ឋលេខាធិការជាប្រធានស្ថាប័ន

**មាត្រា៤.-**

ខុទ្ទកាល័យរបស់នាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី និងរដ្ឋលេខាធិការជាប្រធានស្ថាប័នចំណុះរាជរដ្ឋាភិបាល ជាអង្គភាពដោយឡែកមិនស្ថិតក្នុងរចនាសម្ព័ន្ធអង្គភាពរដ្ឋបាលរបស់រដ្ឋ។

នាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី និងរដ្ឋលេខាធិការជាប្រធានស្ថាប័នមានខុទ្ទកាល័យតែមួយប៉ុណ្ណោះដែលស្ថិតនៅក្រោមការគ្រប់គ្រងនិងការចាត់ចែងផ្ទាល់របស់ខ្លួន។ ដោយឡែកខុទ្ទកាល័យដែលមានមុនអនុក្រឹត្យនេះចូលជាធរមាន ត្រូវអនុវត្តតាមកថាខណ្ឌទី១នៃមាត្រា១៦នៃអនុក្រឹត្យនេះ។

ខុទ្ទកាល័យ ត្រូវបំពេញបេសកកម្មជាជំនួយដល់ថ្នាក់ដឹកនាំសាមីដែលជាអ្នកដឹកនាំនយោបាយលើការងារក្នុងរង្វង់រាជរដ្ឋាភិបាលនិង/ឬរដ្ឋសភា ក៏ដូចជាអ្នកដឹកនាំរដ្ឋបាលក្នុងរាជរដ្ឋាភិបាលឬក្រសួង ស្ថាប័ន។

**មាត្រា៥.-**

ការបង្កើត ការលុប និងការកែសម្រួលខុទ្ទកាល័យនីមួយៗ ព្រមទាំងការតែងតាំងនិងការបញ្ចប់មុខតំណែងមន្ត្រីក្នុងខុទ្ទកាល័យ រួមមាន នាយកខុទ្ទកាល័យ នាយករងខុទ្ទកាល័យ និងមន្ត្រីផ្សេងទៀត ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ថ្នាក់ដឹកនាំដែលគ្រប់គ្រងនិងចាត់ចែងខុទ្ទកាល័យនោះ។

**មាត្រា៦.-**

ខុទ្ទកាល័យនាយករដ្ឋមន្ត្រីមានថវិកាសម្រាប់ដំណើរការការងារក្នុងកញ្ចប់ថវិកាទីស្តីការគណៈរដ្ឋមន្ត្រី។

ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកការងារ ឬ បេសកកម្មពិសេសមានថវិកាសម្រាប់ដំណើរការការងារក្នុងកញ្ចប់ថវិកាទីស្តីការគណៈរដ្ឋមន្ត្រីឬក្នុងកញ្ចប់ថវិការបស់ក្រសួង ស្ថាប័នផ្សេងដែលកំណត់ដោយរាជរដ្ឋាភិបាល។

ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រីដែលទទួលមុខងារដឹកនាំក្រសួង ស្ថាប័នចំណុះរាជរដ្ឋាភិបាលមានថវិកាសម្រាប់ដំណើរការការងារក្នុងកញ្ចប់ថវិការបស់អគ្គលេខាធិការដ្ឋាន ឬអគ្គនាយកដ្ឋាន ឬអង្គភាពទទួលបន្ទុកផ្នែករដ្ឋបាលឬហិរញ្ញវត្ថុរបស់ក្រសួង ស្ថាប័ន។

ខុទ្ទកាល័យទេសរដ្ឋមន្ត្រីទទួលបន្ទុកការងារឬបេសកកម្មពិសេសមានថវិកាសម្រាប់ដំណើរការការងារក្នុងកញ្ចប់ថវិកាទីស្តីការគណៈរដ្ឋមន្ត្រីឬក្នុងកញ្ចប់ថវិកាក្រសួង ស្ថាប័នផ្សេងដែលកំណត់ដោយរាជរដ្ឋាភិបាល។

ខុទ្ទកាល័យទេសរដ្ឋមន្ត្រីដែលទទួលមុខងារដឹកនាំក្រសួង ស្ថាប័នចំណុះរាជរដ្ឋាភិបាល មានថវិកាសម្រាប់ដំណើរការការងារក្នុងកញ្ចប់ថវិការបស់អគ្គលេខាធិការដ្ឋាន ឬអគ្គនាយកដ្ឋាន ឬអង្គភាពទទួលបន្ទុកផ្នែករដ្ឋបាលឬហិរញ្ញវត្ថុរបស់ក្រសួង ស្ថាប័ន។

ខុទ្ទកាល័យរដ្ឋមន្ត្រីឬរដ្ឋលេខាធិការជាប្រធានស្ថាប័ន មានថវិកាសម្រាប់ដំណើរការការងារក្នុងកញ្ចប់ថវិការបស់អគ្គលេខាធិការដ្ឋាន ឬអគ្គនាយកដ្ឋាន ឬអង្គភាពទទួលបន្ទុកផ្នែករដ្ឋបាលឬហិរញ្ញវត្ថុរបស់ក្រសួង ស្ថាប័ន។

**មាត្រា៧.-**

ភារកិច្ចរបស់ខុទ្ទកាល័យមានជាអាទិ៍៖

- រ៉ាប់រងទំនាក់ទំនងរវាងខុទ្ទកាល័យរបស់ថ្នាក់ដឹកនាំក្នុងរាជរដ្ឋាភិបាល ព្រមទាំងទំនាក់ទំនងជាមួយអ្នកតំណាងរាស្ត្រ អង្គភាពរដ្ឋបាលនៃស្ថាប័នសាធារណៈផ្សេងៗទៀត និងប្រព័ន្ធឃោសនាទាំងឡាយ
- ផ្តល់យោបល់ជូននាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការជាប្រធានស្ថាប័នចំណុះរាជរដ្ឋាភិបាល ចំពោះកិច្ចការទូទៅក្នុងរង្វង់រាជរដ្ឋាភិបាលឬក្រសួង ស្ថាប័ននិងចំពោះសំណុំរឿងទាំងឡាយដែលនាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការជាប្រធានស្ថាប័នបានប្រគល់ឱ្យពិនិត្យ។ ភារកិច្ចផ្តល់យោបល់នេះមិនផ្តល់សិទ្ធិឱ្យខុទ្ទកាល័យបំពេញការងារជំនួសក្រសួង ស្ថាប័ន ឬអង្គភាពមានសមត្ថកិច្ចនៅក្នុងក្រសួង ស្ថាប័ន ឬរដ្ឋលេខាធិការដ្ឋានឡើយ
- ផ្សព្វផ្សាយអំពីសកម្មភាព គោលដៅ និងការតម្រង់ទិសផ្សេងៗរបស់ថ្នាក់ដឹកនាំ
- រៀបចំកាលវិភាគរបស់នាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការជាប្រធានស្ថាប័ន ព្រមទាំងសម្របសម្រួលការអនុវត្តការងារឱ្យស្របតាមកាលវិភាគដែលបានកំណត់
- សម្របសម្រួលការរៀបចំសម័យប្រជុំការងាររបស់រាជរដ្ឋាភិបាល អន្តរក្រសួង ឬក្រសួង ស្ថាប័ន
- បញ្ជូនបទបញ្ជានាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការជាប្រធានស្ថាប័នដល់ក្រសួង ស្ថាប័នចំណុះរាជរដ្ឋាភិបាល ឬអង្គភាពទាំងឡាយក្នុងក្រសួង ឬរដ្ឋលេខាធិការដ្ឋាន ផ្អែកលើកម្រិតនៃសមត្ថកិច្ចរបស់ថ្នាក់ដឹកនាំនីមួយៗ
- តាមដាននិងសម្របសម្រួលសកម្មភាពផ្សេងៗរបស់រាជរដ្ឋាភិបាល ក្រសួង ឬរដ្ឋលេខាធិការដ្ឋានដើម្បីសម្រួលការងារឱ្យមានប្រសិទ្ធភាព
- តាមដានការអនុវត្តបញ្ជារបស់នាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការជាប្រធានស្ថាប័នក្នុងរង្វង់សមត្ថកិច្ចនីមួយៗ
- បំពេញការងារផ្សេងៗទៀតតាមការណែនាំរបស់ថ្នាក់ដឹកនាំសាមី។

# ជំពូកទី៣
## មុខតំណែង ចំនួនមន្ត្រីក្នុងមុខតំណែងនីមួយៗ ប្រាក់បំណាច់ប្រចាំខែ និងប្រាក់បេសកកម្មសម្រាប់មន្ត្រីក្នុងខុទ្ទកាល័យ

**មាត្រា៨ .-**

មន្ត្រីខុទ្ទកាល័យត្រូវបំពេញភារកិច្ចពេញម៉ោងដើម្បីឆ្លើយតបនឹងភារកិច្ចរបស់ខុទ្ទកាល័យនិងត្រូវបានផ្តល់នូវប្រាក់បំណាច់ប្រចាំខែផ្អែកលើមុខតំណែងអនុលោមតាមការកំណត់ដូចមានក្នុងតារាងខាងក្រោម៖

**ក- ខុទ្ទកាល័យនាយករដ្ឋមន្ត្រី**

| ល.រ | កម្រិតមុខតំណែង | ឈ្មោះមុខតំណែង | ចំនួនមន្ត្រីក្នុងមុខតំណែង(នាក់) | ប្រាក់បំណាច់ប្រចាំខែ(រៀល) |
|---|---|---|---|---|
| ១ | កម្រិតទី១ | នាយកខុទ្ទកាល័យ | ១ | ៥ ០០០ ០០០ |
| ២ | កម្រិតទី២ | នាយករងខុទ្ទកាល័យ | ផ្អែកលើការចាំបាច់ | ៣ ៥០០ ០០០ |
| ៣ | កម្រិតទី៣ | ទីប្រឹក្សា<br>ពិធីការ | ផ្អែកលើការចាំបាច់ | ២ ៨០០ ០០០ |
| ៤ | កម្រិតទី៤ | ជំនួយការ | ផ្អែកលើការចាំបាច់ | ២ ០០០ ០០០ |
| ៥ | កម្រិតទី៥ | សមាជិកក្រុមលេខា | ផ្អែកលើការចាំបាច់ | ១ ៥០០ ០០០ |

**ខ- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រីមានមុខងារដឹកនាំក្រសួង ស្ថាប័ន**

| ល.រ | កម្រិតមុខតំណែង | ឈ្មោះមុខតំណែង | ចំនួនមន្ត្រីក្នុងមុខតំណែង(នាក់) | ប្រាក់បំណាច់ប្រចាំខែ(រៀល) |
|---|---|---|---|---|
| ១ | កម្រិតទី១ | នាយកខុទ្ទកាល័យ | ១ | ៣ ៥០០ ០០០ |
| ២ | កម្រិតទី២ | នាយករងខុទ្ទកាល័យ | ៣ | ២ ៨០០ ០០០ |
| ៣ | កម្រិតទី៣ | បេសកជន ទីប្រឹក្សាបច្ចេកទេសឬ<br>មុខតំណែងប្រហាក់ប្រហែល | ២ | ២ ១០០ ០០០ |
| ៤ | កម្រិតទី៤ | អនុពន្ធសភា<br>អនុពន្ធសារព័ត៌មានឬ<br>មុខតំណែងប្រហាក់ប្រហែល | ២ | ១ ៥០០ ០០០ |
| ៥ | កម្រិតទី៥ | ជំនួយការឬ<br>មុខតំណែងប្រហាក់ប្រហែល | ២ | ១.១០០.០០០ |
| ៦ | កម្រិតទី៦ | លេខាធិការឬ<br>មុខតំណែងប្រហាក់ប្រហែល | ២ | ១ ០០០ ០០០ |
| សរុប | | | ១២ | |

**គ- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកការងារឬបេសកកម្មពិសេស**

| ល.រ | កម្រិតមុខតំណែង | ឈ្មោះមុខតំណែង | ចំនួនមន្ត្រីក្នុងមុខតំណែង(នាក់) | ប្រាក់បំណាច់ប្រចាំខែ(រៀល) |
|---|---|---|---|---|
| ១ | កម្រិតទី១ | នាយកខុទ្ទកាល័យ | ១ | ៣ ៥០០ ០០០ |
| ២ | កម្រិតទី២ | នាយករងខុទ្ទកាល័យ | ២ | ២ ៨០០ ០០០ |

| | | | | |
|---|---|---|---|---|
| ៣ | កម្រិតទី៣ | បេសកជន ទីប្រឹក្សាបច្ចេកទេសឬ<br>មុខតំណែងប្រហាក់ប្រហែល | ១ | ២ ១០០ ០០០ |
| ៤ | កម្រិតទី៤ | អនុពន្ធសភា<br>អនុពន្ធសារព័ត៌មានឬ<br>មុខតំណែងប្រហាក់ប្រហែល | ១ | ១ ៥០០ ០០០ |
| ៥ | កម្រិតទី៥ | ជំនួយការឬ<br>មុខតំណែងប្រហាក់ប្រហែល | ២ | ១ ១០០ ០០០ |
| ៦ | កម្រិតទី៦ | លេខាធិការឬ<br>មុខតំណែងប្រហាក់ប្រហែល | ២ | ១ ០០០ ០០០ |
| | | សរុប | ៩ | |

ឃ- ខុទ្ទកាល័យទេសរដ្ឋមន្ត្រីមានមុខងារដឹកនាំក្រសួង ស្ថាប័ន

| ល.រ | កម្រិតមុខតំណែង | ឈ្មោះមុខតំណែង | ចំនួនមន្ត្រីក្នុងមុខតំណែង(នាក់) | ប្រាក់បំណាច់ប្រចាំខែ(រៀល) |
|---|---|---|---|---|
| ១ | កម្រិតទី១ | នាយកខុទ្ទកាល័យ | ១ | ២ ៨០០ ០០០ |
| ២ | កម្រិតទី២ | នាយករងខុទ្ទកាល័យ | ២ | ២ ៥០០ ០០០ |
| ៣ | កម្រិតទី៣ | បេសកជន ទីប្រឹក្សាបច្ចេកទេសឬ<br>មុខតំណែងប្រហាក់ប្រហែល | ១ | ២ ១០០ ០០០ |
| ៤ | កម្រិតទី៤ | អនុពន្ធសភា<br>អនុពន្ធសារព័ត៌មានឬ<br>មុខតំណែងប្រហាក់ប្រហែល | ២ | ១ ៥០០ ០០០ |
| ៥ | កម្រិតទី៥ | ជំនួយការឬ<br>មុខតំណែងប្រហាក់ប្រហែល | ១ | ១ ១០០ ០០០ |
| ៦ | កម្រិតទី៦ | លេខាធិការឬ<br>មុខតំណែងប្រហាក់ប្រហែល | ១ | ១ ០០០ ០០០ |
| | | សរុប | ៨ | |

ង- ខុទ្ទកាល័យទេសរដ្ឋមន្ត្រីទទួលបន្ទុកការងារឬបេសកកម្មពិសេស

| ល.រ | កម្រិតមុខតំណែង | ឈ្មោះមុខតំណែង | ចំនួនមន្ត្រីក្នុងមុខតំណែង(នាក់) | ប្រាក់បំណាច់ប្រចាំខែ(រៀល) |
|---|---|---|---|---|
| ១ | កម្រិតទី១ | នាយកខុទ្ទកាល័យ | ១ | ២ ៨០០ ០០០ |
| ២ | កម្រិតទី២ | នាយករងខុទ្ទកាល័យ | ១ | ២ ៥០០ ០០០ |
| ៣ | កម្រិតទី៣ | បេសកជន ទីប្រឹក្សាបច្ចេកទេសឬ<br>មុខតំណែងប្រហាក់ប្រហែល | ១ | ២ ១០០ ០០០ |
| ៤ | កម្រិតទី៤ | អនុពន្ធសភា<br>អនុពន្ធសារព័ត៌មានឬ<br>មុខតំណែងប្រហាក់ប្រហែល | ០ | ១ ៥០០ ០០០ |

| | | | | |
|---|---|---|---|---|
| ៥ | កម្រិតទី៥ | ជំនួយការឬ<br>មុខតំណែងប្រហាក់ប្រហែល | ១ | ១ ១០០ ០០០ |
| ៦ | កម្រិតទី៦ | លេខាធិការឬ<br>មុខតំណែងប្រហាក់ប្រហែល | ១ | ១ ០០០ ០០០ |
| សរុប | | | ៥ | |

ច- ខុទ្ទកាល័យរដ្ឋមន្ត្រីជាប្រធានស្ថាប័ន

| ល.រ | កម្រិត<br>មុខតំណែង | ឈ្មោះមុខតំណែង | ចំនួនមន្ត្រីក្នុង<br>មុខតំណែង(នាក់) | ប្រាក់បំណាច់ប្រចាំខែ(រៀល) |
|---|---|---|---|---|
| ១ | កម្រិតទី១ | នាយកខុទ្ទកាល័យ | ១ | ២ ៨០០ ០០០ |
| ២ | កម្រិតទី២ | នាយករងខុទ្ទកាល័យ | ២ | ២ ៥០០ ០០០ |
| ៣ | កម្រិតទី៣ | បេសកជន ទីប្រឹក្សាបច្ចេកទេសឬ<br>មុខតំណែងប្រហាក់ប្រហែល | ១ | ២ ១០០ ០០០ |
| ៤ | កម្រិតទី៤ | អនុពន្ធសភា<br>អនុពន្ធសារព័ត៌មានឬ<br>មុខតំណែងប្រហាក់ប្រហែល | ២ | ១ ៥០០ ០០០ |
| ៥ | កម្រិតទី៥ | ជំនួយការឬ<br>មុខតំណែងប្រហាក់ប្រហែល | ១ | ១ ១០០ ០០០ |
| ៦ | កម្រិតទី៦ | លេខាធិការឬ<br>មុខតំណែងប្រហាក់ប្រហែល | ១ | ១ ០០០ ០០០ |
| សរុប | | | ៨ | |

ឆ- ខុទ្ទកាល័យរដ្ឋលេខាធិការជាប្រធានស្ថាប័ន

| ល.រ | កម្រិត<br>មុខតំណែង | ឈ្មោះមុខតំណែង | ចំនួនមន្ត្រីក្នុង<br>មុខតំណែង(នាក់) | ប្រាក់បំណាច់ប្រចាំខែ(រៀល) |
|---|---|---|---|---|
| ១ | កម្រិតទី១ | នាយកខុទ្ទកាល័យ | ១ | ២ ៨០០ ០០០ |
| ២ | កម្រិតទី២ | នាយករងខុទ្ទកាល័យ | ១ | ២ ៥០០ ០០០ |
| ៣ | កម្រិតទី៣ | បេសកជន ទីប្រឹក្សាបច្ចេកទេសឬ<br>មុខតំណែងប្រហាក់ប្រហែល | ១ | ២ ១០០ ០០០ |
| ៤ | កម្រិតទី៤ | អនុពន្ធសភា<br>អនុពន្ធសារព័ត៌មានឬ<br>មុខតំណែងប្រហាក់ប្រហែល | ០ | ១ ៥០០ ០០០ |
| ៥ | កម្រិតទី៥ | ជំនួយការឬ<br>មុខតំណែងប្រហាក់ប្រហែល | ១ | ១ ១០០ ០០០ |
| ៦ | កម្រិតទី៦ | លេខាធិការឬ<br>មុខតំណែងប្រហាក់ប្រហែល | ១ | ១ ០០០ ០០០ |
| សរុប | | | ៥ | |

នាយកខុទ្ទកាល័យ ត្រូវរៀបចំការបែងចែកភារកិច្ចនាយករងខុទ្ទកាល័យនិងមន្ត្រីក្នុងខុទ្ទកាល័យដើម្បីធានានូវការអនុវត្តភារកិច្ចរបស់ខុទ្ទកាល័យឱ្យមានប្រសិទ្ធភាព។

ដោយឡែករដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រីម្នាក់ៗ អាចមានមន្ត្រីក្នុងមុខតំណែងជាជំនួយការយ៉ាងច្រើនត្រឹម ៤(បួន)រូប។ រដ្ឋលេខាធិការជាសមាជិករាជរដ្ឋាភិបាលម្នាក់ៗ អាចមានមន្ត្រីក្នុងមុខតំណែងជាជំនួយការត្រឹម១(មួយ)រូបប៉ុណ្ណោះ។ មន្ត្រីជំនួយការទាំងនេះ ត្រូវទទួលបានប្រាក់បំណាច់ប្រចាំខែដូចមន្ត្រីក្នុងមុខតំណែងជំនួយការក្នុងកម្រិតទី៥របស់ខុទ្ទកាល័យរដ្ឋមន្ត្រី ព្រមទាំងត្រូវស្ថិតនៅក្រោមការគ្រប់គ្រងនិងការចាត់ចែងផ្ទាល់របស់ថ្នាក់ដឹកនាំសាមីនិងស្ថិតក្រោមបទប្បញ្ញត្តិដែលមានចែងសម្រាប់មន្ត្រីខុទ្ទកាល័យ។

**មាត្រា៩.-**

នាយករដ្ឋមន្ត្រីអាចប្រើប្រាស់មន្ត្រីក្នុងខុទ្ទកាល័យដើម្បីបំពេញភារកិច្ចក្នុងមុខតំណែងដែលមានកំណត់ក្នុងមាត្រា៨ខាងលើ ផ្អែកលើភាពចាំបាច់តាមការសម្រេចរបស់នាយករដ្ឋមន្ត្រី។

ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី និងរដ្ឋលេខាធិការជាប្រធានស្ថាប័ន ព្រមទាំងរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងរដ្ឋលេខាធិការជាសមាជិករាជរដ្ឋាភិបាលអាចប្រើប្រាស់មន្ត្រីក្នុងមុខតំណែងនីមួយៗដោយទទួលបានប្រាក់បំណាច់ប្រចាំខែតាមប្រភេទមុខតំណែងនិងផ្អែកលើចំនួនដែលមានកំណត់ក្នុងមាត្រា៨ខាងលើនេះ។ ដោយឡែកចំនួនមន្ត្រីដែលត្រូវបានកំណត់សម្រាប់មុខតំណែងក្នុងកម្រិតទី២ កម្រិតទី៣ កម្រិតទី៤ ឬកម្រិតទី៥ អាចត្រូវយកមកប្រើប្រាស់ក្នុងមុខតំណែងកម្រិតទាបជាងបាន ដោយផ្តល់ប្រាក់បំណាច់តាមប្រភេទមុខតំណែងកម្រិតទាបនោះ។ ចំនួនសរុបរបស់មន្ត្រីក្នុងខុទ្ទកាល័យ ត្រូវបានកំហិតមិនឱ្យលើសចំនួនកំណត់ក្នុងមាត្រា៨ខាងលើនេះឡើយ។

**មាត្រា១០.-**

ប្រាក់បំណាច់ប្រចាំខែដែលមានកំណត់ក្នុងតារាងនៃមាត្រា៨នៃអនុក្រឹត្យនេះ ត្រូវអនុវត្តចាប់ពីថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៧តទៅ សម្រាប់តែមុខតំណែងនិងត្រឹមចំនួនមន្ត្រីក្នុងមុខតំណែងដែលបានកំណត់ដោយអនុក្រឹត្យនេះនិងអនុលោមតាមបទប្បញ្ញត្តិនៃមាត្រា១៦នៃអនុក្រឹត្យនេះ។

ក្រៅពីមន្ត្រីខុទ្ទកាល័យដែលត្រូវទទួលការបើកផ្តល់ប្រាក់បំណាច់ប្រចាំខែសម្រាប់មន្ត្រីខុទ្ទកាល័យដែលមានចែងក្នុងកថាខណ្ឌទី១ខាងលើនេះ មន្ត្រីខុទ្ទកាល័យផ្សេងទៀត ត្រូវបន្តទទួលប្រាក់បំណាច់ប្រចាំខែអនុលោមតាម៖

- ព្រះរាជក្រឹត្យស្តីពីការគ្រប់គ្រងនិងការបើកផ្តល់ប្រាក់បំណាច់ជូនទីប្រឹក្សា ជំនួយការ លេខាធិការ និងមន្ត្រីដែលមានឋានៈស្មើ ឬ
- បទប្បញ្ញត្តិរបស់រាជរដ្ឋាភិបាលដែលពាក់ព័ន្ធនឹងបៀវត្សមូលដ្ឋាននិងប្រាក់បន្ទាប់បន្សំនៃបៀវត្សរបស់មន្ត្រីរាជការដែលមានជាធរមាន។

មន្ត្រីខុទ្ទកាល័យអាចជ្រើសរើសយកប្រាក់បំណាច់តាមការកំណត់ក្នុងអនុក្រឹត្យនេះឬប្រាក់បំណាច់មុខងារផ្សេងទៀតតែមួយប៉ុណ្ណោះ។

**មាត្រា១១.-**

មន្ត្រីខុទ្ទកាល័យដែលមានមុខតំណែងឋានៈស្មើឬមុខតំណែងសាធារណៈផ្សេងទៀតដែលមានកំណត់ក្នុងអនុក្រឹត្យលេខ២១៦ អនក្រ.បក ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៤ ស្តីពីប្រាក់បេសកកម្មនៅក្នុងនិង

ក្រៅប្រទេសសម្រាប់រដ្ឋបាលថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ត្រូវទទួលបានប្រាក់បេសកកម្មអនុលោមតាមបទប្បញ្ញត្តិនៃអនុក្រឹត្យលេខ២១៦ អនក្រ.បក ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៤ ស្តីពីប្រាក់បេសកកម្មនៅក្នុងនិងក្រៅប្រទេសសម្រាប់រដ្ឋបាលថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។

មន្ត្រីខុទ្ទកាល័យដែលជាមន្ត្រីរាជការស្ថិតនៅក្រៅក្របខណ្ឌដើម និង ដែលមិនស្ថិតក្នុងកថាខណ្ឌទី១ខាងលើ ត្រូវទទួលបានប្រាក់បេសកកម្មផ្អែកលើមុខតំណែងមន្ត្រីរាជការរបស់មន្ត្រីសាមីមុនពេលចូលបម្រើការងារក្នុងខុទ្ទកាល័យ។

មន្ត្រីខុទ្ទកាល័យដែលមិនស្ថិតក្នុងកថាខណ្ឌទី១ និង កថាខណ្ឌទី២ខាងលើនេះ ត្រូវទទួលបានប្រាក់បេសកកម្មដូចមន្ត្រីជាប់កិច្ចសន្យាអនុលោមតាមបទប្បញ្ញត្តិនៃអនុក្រឹត្យលេខ២១៦ អនក្រ.បក ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៤ ស្តីពីប្រាក់បេសកកម្មនៅក្នុងនិងក្រៅប្រទេសសម្រាប់រដ្ឋបាលថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។

**មាត្រា១២.-**

មន្ត្រីបំពេញភារកិច្ចក្នុងមុខតំណែងដែលមានកំណត់ក្នុងមាត្រា៨នៃអនុក្រឹត្យនេះ មិនមានលក្ខណៈអចិន្ត្រៃយ៍ឡើយនិងអាចត្រូវបានបញ្ចប់មុខតំណែងគ្រប់ពេលដោយពុំចាំបាច់បញ្ជាក់ពីមូលហេតុអ្វីទាំងអស់។

មន្ត្រីខុទ្ទកាល័យត្រូវបានបញ្ចប់ពីមុខតំណែងរបស់ខ្លួននៅពេលមានការផ្លាស់ប្តូរមុខតំណែងនាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការជាប្រធានស្ថាប័ន។

មន្ត្រីខុទ្ទកាល័យដែលពីមុនមិនមែនជាមន្ត្រីរាជការក្របខណ្ឌ ពុំអាចទាមទារក្របខណ្ឌមន្ត្រីរាជការនៅពេលបញ្ចប់មុខតំណែងដោយយោលទៅលើការតែងតាំងខ្លួនជាមន្ត្រីខុទ្ទកាល័យនោះឡើយ។

**មាត្រា១៣.-**

មន្ត្រីរាជការក្នុងក្របខណ្ឌ រួមទាំងមន្ត្រីរាជការស៊ីវិល មន្ត្រីនគរបាលជាតិ មន្ត្រីពន្ធនាគារនៃក្រសួងមហាផ្ទៃ និងយោធិននៃកងយោធពលខេមរភូមិន្ទ ដែលត្រូវបានតែងតាំងក្នុងមុខតំណែងណាមួយក្នុងខុទ្ទកាល័យ ត្រូវដាក់ឱ្យស្ថិតនៅក្រៅក្របខណ្ឌដើម។ ដោយឡែកមន្ត្រីខុទ្ទកាល័យដែលមានមុនពេលអនុក្រឹត្យនេះចូលជាធរមាន ត្រូវអនុវត្តតាមកថាខណ្ឌទី១នៃមាត្រា១៦នៃអនុក្រឹត្យនេះ។

ក្នុងរយៈពេលបំពេញការងារនៅខុទ្ទកាល័យ មន្ត្រីរាជការ ត្រូវបានដំឡើងថ្នាក់និង/ឬឋានន្តរស័ក្តិដោយស្វ័យប្រវត្តិនៅថ្ងៃទី១៣ ខែមេសានៃឆ្នាំនីមួយៗផ្អែកលើអតីតភាពការងារ ២(ពីរ)ឆ្នាំ ព្រមទាំងត្រូវបានគិតអតីតភាពសម្រាប់ទទួលសោធននិវត្តន៍ក្នុងរយៈពេលបំពេញភារកិច្ចក្នុងខុទ្ទកាល័យ។

ក្រោយពេលបញ្ចប់ពីមុខតំណែងក្នុងខុទ្ទកាល័យ មន្ត្រីសាមីត្រូវដាក់ពាក្យសុំចូលបម្រើការងារក្នុងក្របខណ្ឌដើមវិញ ដោយផ្តល់ជូនជាស្វ័យប្រវត្តិនូវឋានន្តរស័ក្តិនិងថ្នាក់អនុលោមតាមកថាខណ្ឌខាងលើ ព្រមទាំងប្រាក់បំណាច់មុខងារផ្អែកលើមុខតំណែងក្នុងមុខងារសាធារណៈដែលមានមុនពេលការតែងតាំងចូលបម្រើការងារក្នុងខុទ្ទកាល័យ។ មន្ត្រីសាមី នឹងទទួលបានសិទ្ធិអាទិភាពក្នុងការតែងតាំងក្នុងមុខតំណែងដើមឬមុខតំណែងទំនេរប្រហាក់ប្រហែលនឹងមុខតំណែងដើមផ្អែកលើរចនាសម្ព័ន្ធគ្រប់គ្រងរបស់ក្រសួង ស្ថាប័ននិងការសម្រេចរបស់ប្រធានស្ថាប័ន។

**មាត្រា១៤.-**

ការបង្កើត ការលុប និងការកែសម្រួលមុខតំណែងនិងចំនួនមន្ត្រីក្នុងមុខតំណែងនីមួយៗ ព្រមទាំងប្រាក់បំណាច់ប្រចាំខែរបស់មន្ត្រីក្នុងខុទ្ទកាល័យ ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា១៥.-**

ក្រៅពីការប្រើប្រាស់មន្ត្រីក្នុងមុខតំណែងដែលមានកំណត់ក្នុងមាត្រា៨នៃអនុក្រឹត្យនេះ ទីស្តីការគណៈរដ្ឋមន្ត្រី អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន និងអង្គភាពទទួលបន្ទុកផ្នែករដ្ឋបាលរបស់ក្រសួង ស្ថាប័ន ត្រូវផ្តល់មន្ត្រីរាជការក្របខណ្ឌនិងមន្ត្រីជាប់កិច្ចសន្យារបស់ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួង ឬរដ្ឋលេខាធិការដ្ឋាន ជូនខុទ្ទកាល័យនិងសមាជិករាជរដ្ឋាភិបាលផ្អែកលើភាពចាំបាច់នៃភារកិច្ច ដើម្បីរ៉ាប់រងលើកិច្ចការផ្នែកផ្គត់ផ្គង់និងរដ្ឋបាល។

មុខតំណែងសម្រាប់កិច្ចការផ្នែកផ្គត់ផ្គង់និងរដ្ឋបាល រួមមាន៖

- មន្ត្រីពិធីការ
- អ្នកបើកបរ
- លេខាធិការការិយាល័យ
- ការីកុំព្យូទ័រ
- អ្នកបកប្រែភាសា
- អ្នកជំនាញផ្សេងទៀតដែលជាតម្រូវការនៃភារកិច្ចរបស់ខុទ្ទកាល័យ។

## ជំពូកទី៤

## អន្តរប្បញ្ញត្តិ

**មាត្រា១៦.-**

ខុទ្ទកាល័យ និង មន្ត្រីខុទ្ទកាល័យដែលមានមុនពេលអនុក្រឹត្យនេះចូលជាធរមាននៅមានសុពលភាពបន្តរហូតដល់ពេលមានការបង្កើត ការលុប និងការកែសម្រួលខុទ្ទកាល័យជាថ្មីដែលត្រូវអនុវត្តអនុលោមតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ។

ការបើកផ្តល់ប្រាក់បំណាច់ប្រចាំខែតាមការកំណត់ថ្មីក្នុងមាត្រា៨នៃអនុក្រឹត្យនេះ ជូនមន្ត្រីខុទ្ទកាល័យបច្ចុប្បន្នត្រូវអនុវត្តផ្អែកលើមុខតំណែងនិងចំនួនមន្ត្រីក្នុងមុខតំណែងដែលបានកំណត់ក្នុងមាត្រា៨នៃអនុក្រឹត្យនេះ លើកលែងតែចំនួនមន្ត្រីខុទ្ទកាល័យនាយករដ្ឋមន្ត្រីនិងមន្ត្រីខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី ត្រូវកំណត់តាមការសម្រេចរបស់នាយករដ្ឋមន្ត្រីផ្អែកលើសំណើរបស់ក្រសួងមុខងារសាធារណៈនិងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី៥

## អវសានប្បញ្ញត្តិ

**មាត្រា១៧.-**

មាត្រា១៦ មាត្រា១៧ មាត្រា១៨ មាត្រា១៩ មាត្រា២០ មាត្រា២១ មាត្រា២២ និងមាត្រា២៣ នៃអនុក្រឹត្យលេខ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន និង បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា១៨ ._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័ន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

នៅរាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ**

**ពេជ្រ ប៊ុនធិន**

**កន្លែងទទួល ៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៨
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ